គណនេយ្យភាពសង្គម
នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ករណីសិក្សា

## ការអភិវឌ្ឍរបស់សាលាបឋមសិក្សា ហ៊ុន សែន យាយសល់ តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គម







គជអប
NCDD

Australian Aid

THE WORLD BANK

# ករណីសិក្សា

## ការអភិវឌ្ឍរបស់សាលាបឋមសិក្សា ហ៊ុន សែន យាយសល់ តាមរយៈការអនុវត្តការងារគណនេយ្យភាពសង្គម

វិស័យអប់រំដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សដែលជាមូលដ្ឋានគ្រឹះចាំបាច់មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ ផ្អែកលើសារៈសំខាន់នៃការងារអប់រំ និងកាតព្វកិច្ចរបស់រដ្ឋាភិបាលដែលត្រូវធានាដល់ការរៀបចំនិងការផ្តល់សេវាអប់រំប្រកបដោយគុណភាពជូនប្រជាពលរដ្ឋគ្រប់រូបដូចដែលបានកំណត់ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាលរបស់រាជរដ្ឋាភិបាលដែលបានដាក់ឱ្យអនុវត្តនាពេលកន្លងមក ព្រមទាំងកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភាដែលបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ ឯកឧត្តមកិត្តិទេសាភិបាលបណ្ឌិត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អាទិភាពជាចម្បងលើការជំរុញ និងការលើកកម្ពស់ការផ្តល់សេវាអប់រំប្រកបដោយគុណភាព ប្រសិទ្ធភាព បរិយាប័ន្ន និងសមធម៌សង្គម។ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ ការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងការជួយជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់ និងចាំបាច់ក្នុងការចូលរួមចំណែកធ្វើឱ្យប្រសើរឡើងក្នុងការផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ប្រសិទ្ធភាព តាមរយៈការលើកកម្ពស់តម្លាភាព ការចូលរួមរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបទៅនឹងតម្រូវការនានារបស់ប្រជាពលរដ្ឋផងដែរ។

សាលាបឋមសិក្សា ហ៊ុន សែន យាយសល់ មានទីតាំងស្ថិតនៅនៅភូមិយាយសល់ ឃុំពោធិ៍រៀង ស្រុកពោធិ៍រៀង នៃខេត្តព្រៃវែង។ សាលាបឋមសិក្សា ហ៊ុន សែន យាយសល់ បាននិងកំពុងអនុវត្តការងារគណនេយ្យភាពសង្គម ដែលចាប់ផ្តើមតាំងពីឆ្នាំ២០២០ រហូតមកដល់ពេលបច្ចុប្បន្ន។ លោក វី ចាន់ថន នាយកសាលាបឋមសិក្សា ហ៊ុន សែន យាយសល់ បានមានប្រសាន៍អំពីសមិទ្ធផល និងដំណើរការរបស់សាលាថា “បច្ចុប្បន្នសាលារៀនមានអគារសិក្សាចំនួន២ខ្នង ១១បន្ទប់ និងអគារទីចាត់ការ១ខ្នង ២បន្ទប់ បង្គន់អនាម័យ ២ខ្នង ៧បន្ទប់។ សាលារៀននេះគ្របដណ្តប់លើ ភូមិចំនួន០២ នៃឃុំពោធិ៍រៀង គឺ៖ ភូមិយាយសល់ និងភូមិពោធិ៍រៀងត្បូងមានប្រជាពលរដ្ឋសរុបចំនួន២.២៦៧នាក់ ស្រី១.១៤៧នាក់។ សាលាមានបុគ្គលិកពេញសិទ្ធិចំនួន១១នាក់(គ្រូទទួលបន្ទុកថ្នាក់ចំនួន០៩នាក់ស្រី ០៥នាក់) មានចំនួនសិស្សសរុបចំនួន៣៥៦នាក់(សិស្សប្រុសចំនួន១៦៥នាក់ និងសិស្សស្រីចំនួន១៩១នាក់)។”

”ចំពោះការងារគណនេយ្យភាពសង្គម សាលាបានអនុវត្តចាប់តាំងពីឆ្នាំ២០២០ ដែលបានអនុវត្តសកម្មភាពសំខាន់ៗមួយចំនួនដូចជា ការផ្តល់ព័ត៌មានអំពីទិន្នន័យលទ្ធផលបំពេញការងារ ថវិកាចំណូល ចំណាយ ធ្វើការបិទផ្សាយផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋនៅក្នុងបរិវេណសាលា ចូលរួមកិច្ចប្រជុំដាក់ពិន្ទុវាយតម្លៃខ្លួនឯងដែលមានលោកគ្រូ អ្នកគ្រូដែលជាបុគ្គលិករបស់សាលា ចូលរួមសម្របសម្រួលក្នុងការអញ្ជើញសិស្ស និងអាណាព្យាបាលដើម្បីចូលរួមកិច្ចប្រជុំដាក់ពិន្ទុវាយតម្លៃការផ្តល់សេវាចូលរួមកិច្ចប្រជុំរួមដែលបង្កើតបានជាផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីកែលម្អការផ្តល់សេវារបស់សាលាបឋមសិក្សា និងលើកឡើងពីតម្រូវការនានា ចូលរួមជាសមាជិកគណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គមរបស់ឃុំពោធិ៍រៀង និងចូលរួមកិច្ចប្រជុំនានារបស់គណៈកម្មាធិការផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីពិនិត្យមើលវឌ្ឍនភាព បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយនានាក្នុងការអនុវត្តផែនការជាប្រចាំផងដែរ។”



លោក វី ចាន់ថន នាយកសាលាបឋមសិក្សា ហ៊ុន សែន យាយសល់

លោកបានបន្តទៀតផងដែរអំពីសមិទ្ធផលដែលកើតចេញពីផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម និងការផ្លាស់ប្តូរជាវិជ្ជមានបន្ទាប់ពីការអនុវត្តការងារគណនេយ្យភាពសង្គមដូចជា៖ ការសាងសង់ខ្លោងទ្វារសាលាថ្មី ការចាក់ដីបំពេញបន្ថែម សិស្សានុសិស្សទទួលបានសៀវភៅសិក្សាគោលគ្រប់គ្រាន់ លោកគ្រូ អ្នកគ្រូគោរពពេលវេលាការងារបានត្រឹមត្រូវ សាលាបានបង្កើតកម្មវិធីជួយសិស្សរៀនយឺត និងជួយសិស្សមកពីគ្រួសារជួបការលំបាក (សិស្សក្រីក្ររៀនពូកែទទួលបានថវិកាប្រចាំឆ្នាំ) សាលាបានអនុវត្តនូវការគ្រប់គ្រងកាកសំណល់ប្លាស្ទិកដោយបង្កើតទម្លាប់ឱ្យសិស្សចេះបែងចែកប្រភេទសំរាមបានយ៉ាងត្រឹមត្រូវ។ ជាមួយគ្នានេះដែរ អាណាព្យាបាល និងប្រជាពលរដ្ឋមានការយល់ដឹងច្រើនទៅលើព័ត៌មានអំពីសិទ្ធិ ស្តង់ដា និងការបំពេញការងាររបស់សាលាបឋមសិក្សាដែលមាននៅក្នុងផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ និងមានការចូលរួមច្រើនជាងមុនពាក់ព័ន្ធទៅនឹងការងារអភិវឌ្ឍន៍របស់សាលា។ ក្នុងនោះផងដែរ ប្រជាពលរដ្ឋហ៊ានក្នុងការផ្តល់ព័ត៌មាន និងមតិយោបល់ដោយផ្ទាល់ដល់លោកគ្រូ អ្នកគ្រូ និងគណៈកម្មការគ្រប់គ្រងសាលាអំពីតម្រូវការរបស់ពួកគាត់ និងព័ត៌មាននៃការសិក្សារបស់កូន និងចៅរបស់ពួកគាត់។

អ្នកគ្រូ វ៉ាន់ សុភ័ក្ត គ្រូបង្រៀននៅក្នុងសាលាបឋមសិក្សា ហ៊ុន សែន យាយសល់ បានបង្ហាញនូវចំណាប់អារម្មណ៍ទៅលើការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងសាលាថា "នាងខ្ញុំឃើញថាមានការផ្លាស់ប្តូរជាវិជ្ជមានជាច្រើនដូចជា៖ វិធីសាស្ត្របង្រៀន ទំនាក់ទំនង ការកែលម្អបរិស្ថាន របៀបធ្វើការងារ និងការដោះស្រាយបញ្ហានានាមានភាពប្រសើរជាងមុន។ ចំពោះការផ្តល់សេវា និងការបំពេញការងាររបស់លោកគ្រូ អ្នកគ្រូ មានភាពល្អប្រសើរជាងមុន ពោលគឺ បង្រៀនប្រកបដោយមនសិការវិជ្ជាជីវៈគ្រូបង្រៀន សាមគ្គីភាពរាល់ពេលធ្វើសកម្មភាព និងផ្តោតលើគុណភាពសិក្សា វិន័យ សីលធម៌ និងសុជីវធម៌។"



អ្នកគ្រូ វ៉ាន់ សុភ័ក្ត គ្រូបង្រៀនសាលាបឋមសិក្សា ហ៊ុន សែន យាយសល់

"នាងខ្ញុំមានការពេញចិត្តលើការគ្រប់គ្រងសាលារបស់លោកនាយកសាលាដោយសារតែគាត់បានជួយណែនាំឱ្យលោកគ្រូ អ្នកគ្រូអនុវត្តទៅលើការងាររបស់គាត់បានត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ គ្រប់គ្រងថវិកាចំណូល ចំណាយរបស់សាលាបានត្រឹមត្រូវ និងបានបិទផ្សាយព័ត៌មានទាក់ទងនឹងចំណូលចំណាយនៅលើផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋរបស់សាលាជាប្រចាំ។ វិធីសាស្ត្រក្នុងការទំនាក់ទំនង និងដោះស្រាយបញ្ហាមានភាពប្រសើរជាងមុន ដូចជាការកសាងខ្លោងទ្វារសាលាត្រូវការចំណាយថវិកាច្រើនដោយលោកនាយកបានធ្វើការទំនាក់ទំនង និងកៀរគរថវិកាពីប្រជាពលរដ្ឋក៏ដូចជាសប្បុរសជនអ្នកពាក់ព័ន្ធនានាដើម្បីឱ្យសម្រេចបានសមិទ្ធផល។"

លោកស្រី លេញ វួចនី ប្រជាពលរដ្ឋរស់នៅក្នុងភូមិពោធិ៍រៀង ឃុំពោធិ៍រៀង និងជាអាណាព្យាបាលសិស្សក្នុងសាលាបឋមសិក្សា ហ៊ុន សែន យាយសល់ បានមានប្រសាសន៍ថា "នាងខ្ញុំបានចូលរួមដាក់ពិន្ទុវាយតម្លៃលើការផ្តល់សេវារបស់សាលារៀន។ តាមរយៈការដាក់ពិន្ទុវាយតម្លៃនេះនាងខ្ញុំមានភាពពេញចិត្ត ដែលនាងខ្ញុំមានឱកាសបានបញ្ចេញនូវមតិយោបល់ក៏ដូចជាសំណូមពរ ទៅលើតម្រូវការរបស់សិស្ស និងអាណាព្យាបាលដល់សាលា ហើយខាងសាលា និងអ្នកពាក់ព័ន្ធ បានឆ្លើយតបនូវតម្រូវការនិងសំណូមពររបស់អាណាព្យាបាលនិងសិស្សពិតមែន។"



លោកស្រី លេញ វួចនី ប្រជាពលរដ្ឋរស់នៅក្នុងភូមិពោធិ៍រៀង

ចំពោះទិសដៅបន្តក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមក្នុងសាលារៀន លោកនាយកបានលើកឡើងយ៉ាងមុតមាំថា ដើម្បីធានាបាននូវនិរន្តរភាពនៃការអនុវត្តការងារគណនេយ្យសង្គមនៅសាលាបឋមសិក្សា យើងត្រូវមានស្មារតីទទួលខុសត្រូវលើការងារប្រកបដោយគំនិតច្នៃប្រឌិត ព្រោះថាគណនេយ្យភាពសង្គមជាកាតព្វកិច្ចសំខាន់របស់អ្នកផ្តល់សេវាត្រូវអនុវត្ត។ ជាមួយគ្នានេះដែរ សាលានឹងធ្វើការផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិ ស្តង់ដា ការបំពេញការងារ ថវិកា និងព័ត៌មាននានារបស់សាលាបឋមសិក្សាតាមរយៈប្រព័ន្ធឌីជីថល ឬបណ្តាញសង្គម ពង្រឹងទំនាក់ទំនង និងការចូលរួមរបស់ប្រជាពលរដ្ឋតាមរយៈកិច្ចប្រជុំនានារបស់សាលា។ ទន្ទឹមនឹងនេះ លោកក៏សុំណូមពរដល់ក្រសួង ស្ថាប័នអនុវត្តនៅថ្នាក់ជាតិ អ្នកពាក់ព័ន្ធជួយបន្តលើកទឹកចិត្តគ្រប់រូបភាពដល់អ្នកផ្តល់សេវាដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលបានស្នើសុំក្នុងផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម ផ្តល់ដូចជាប័ណ្ណសរសើរដល់អង្គភាពផ្តល់សេវាដែលអនុវត្តបានល្អ ផ្តល់ជាសម្ភារៈការិយាល័យ និងបណ្ណាល័យបន្ថែម ផ្តល់វគ្គបណ្តុះបណ្តាលខ្លីអំពីការប្រើប្រាស់បណ្តាញសង្គម និងប្រព័ន្ធបច្ចេកវិទ្យាឌីជីថលដើម្បីអភិវឌ្ឍន៍ក្នុងការផ្សព្វផ្សាយជូនប្រជាពលរដ្ឋបន្ថែមផងដែរ។

ការអភិវឌ្ឍនៅក្នុងសាលា និងការផ្លាស់ប្តូរជាវិជ្ជមាន តាមរយៈការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមរបស់សាលាបឋមសិក្សា ហ៊ុន សែន យាយសល់ ជាសមិទ្ធផលកើតចេញពីការខិតខំប្រឹងប្រែងពីអ្នកពាក់ព័ន្ធទាំងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ ក៏ដូចជាប្រជាពលរដ្ឋ និងសហគមន៍នៅមូលដ្ឋានហើយ ជាគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ ជាមួយនឹងរដ្ឋបាលមូលដ្ឋាន “មានគណនេយ្យភាពសង្គម ជាតិមានអនាគតភ្លឺស្វាង” ។





